# ឯកសារសង្ខេបអំពីដៃគូអនុវត្តគម្រោង
# ផ្នែកពិការភាព

| |
|---|
| **សង្ខេបគម្រោង** |
| **សាខាក្រុមហ៊ុនអ៊ែជ្យាយល៍ ឌីវេឡុមមិន គ្រុប** (Agile) កំពុងធ្វើការជាដៃគូជាមួយរដ្ឋាភិបាល អង្គការជនពិការ និងវិស័យឯកជន ដើម្បីចូលរួមគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព (២០១៩-២០២៣)។ គម្រោងនេះ ផ្តោតសំខាន់លើការបង្កើនសមត្ថភាពនៃការធ្វើអាជីវកម្មរបស់ស្រ្តីមានពិការភាព។ |
| **លទ្ធផលរំពឹងទុករបស់គម្រោង** |
| • សហគ្រិនស្រ្តីដែលមានពិការភាពបានបង្កើនសមត្ថភាពក្នុងការធ្វើអាជីវកម្ម បណ្តាញមិត្តគាំទ្រ និងការយល់ពីការរួមចំណែកផ្នែកសេដ្ឋកិច្ចដល់សង្គម។<br>• សហគ្រិនស្រ្តីដែលមានពិការភាពបានបង្កើនការទទួលផ្ទាល់ និងតាមឌីជីថល ដើមទុនហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់អាជីវកម្មថ្មី និងឱកាសបង្កើតការងារដោយខ្លួនឯង។<br>• អ្នកបង្កើតគោលនយោបាយសំខាន់ៗ បានបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍សេដ្ឋកិច្ចរបស់សហគ្រិនស្រ្តីដែលមានពិការភាពដល់សង្គម រួមទាំងយុទ្ធសាស្រ្តគោលនយោបាយដើម្បីបង្កើនឱកាសហិរញ្ញវត្ថុ សម្រាប់សហគ្រិនស្រ្តីដែលមានពិការភាព។ |
| **កិច្ចអន្តរាគមន៍សំខាន់ៗ** |
| • ផ្តល់កម្មវិធីបណ្តុះបណ្តាលស្តីពីការបង្កើតអាជីវកម្មដល់សហគ្រិនស្រ្តីដែលមានពិការភាព។<br>• បង្កើត និងទ្រទ្រង់បណ្តាញ សហគ្រិនស្រ្តីដែលមានពិការភាព។<br>• អនុវត្ត និងផ្សព្វផ្សាយការស្រាវជ្រាវ លើការទទួលសេវាហិរញ្ញវត្ថុសម្រាប់សហគ្រិនស្រ្តីដែលមានពិការភាព។<br>• ប្រមូលសាច់រឿងដែលជោគជ័យ មេរៀនដែលរៀនសូត្រ និងរៀបចំវេទិកាសម្រាប់ផ្តល់ព័ត៌មាន និងបង្កើតឥទ្ធិពលដល់អ្នកបង្កើតគោលនយោបាយអំពី សហគ្រិនភាពសម្រាប់ស្ត្រីមានពិការភាព។ |
| **កិច្ចអន្តរាគមន៍ជាពិសេស ចំពោះការទប់ស្កាត់ការរីករាលដាលនៃមេរោគ កូវីដ-១៩** |
| • ផ្តល់វគ្គបណ្តុះបណ្តាលពីចម្ងាយអំពីបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានដល់សហគ្រិនស្រ្តីដែលមានពិការភាព។ |

| | |
|---|---|
| • ធ្វើការស្ទង់មតិបែបគុណភាពបន្ទាន់មួយអំពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើសហគ្រិនស្ត្រីដែលមានពិការភាព។ | |
| **ក្រុមគោលដៅ** | |
| • ក្រុមគោលដៅផ្ទាល់៖ ស្ត្រីដែលពិការភាពរស់នៅទីក្រុង ជាពិសេសសហគ្រិនស្ត្រីដែលមានពិការភាពដែលមានអាយុពី ១៨ ដល់ ៣៥ឆ្នាំ។<br>• ក្រុមគោលដៅប្រយោល៖ សមាជិកគ្រួសាររបស់សហគ្រិនស្ត្រីមានពិការភាព និងសហគមន៍នៃជនមានពិការភាព។ | |
| **តំបន់គោលដៅ** | |
| រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ និងខេត្តបាត់ដំបង។ | |
| **ដៃគូអនុវត្តគម្រោង** | |
| មជ្ឈមណ្ឌលជីវិតរស់នៅដោយឯករាជ្យនៃជនពិការភ្នំពេញ (PPCIL) ការពង្រឹងសិទ្ធិអំណាច និងឱកាសការងារសម្រាប់ជនពិការ (EEPD) អង្គការជនពិការកម្ពុជា (CDPO) | |
| **រយៈពេលអនុវត្តគម្រោង** | |
| ខែតុលា ឆ្នាំ២០១៩ ដល់ខែធ្នូ ឆ្នាំ២០២០ | |
| **ថវិកាគម្រោង** | |
| ថវិកាសរុប៖ ១៧៨,២០៥ ដុល្លារអូស្ត្រាលី (ថវិកាពី ACCESS៖ ១៧២,៦៤៥) | |
| **ព័ត៌មានទំនាក់ទំនង** | |
| សហគ្រាសសង្គម អ៊ែជ្យាយល៍<br>លោក **ចូន អៀន** (Mr. Ian JONES)<br>នាយកប្រតិបត្តិ<br>ទូរស័ព្ទ៖ (៨៥៥)៧៨ ៩៧២ ៥៨០<br>អ៊ីម៉ែល៖ ian@agiledg.com | កម្មវិធី ACCESS<br>លោក **ជូ វិវឌ្ឍន៍**<br>ប្រធានផ្នែកពិការភាព<br>ទូរស័ព្ទ៖ (៨៥៥) ១២ ៩១៥ ៦៧៤<br>អ៊ីម៉ែល៖ vivath.ch@accesscambodia.org |

គម្រោងនេះឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី សហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីសេវាប្រកបដោយនិរន្តរភាព និងសមធម៌ (ACCESS)។

ខែឧសភា ឆ្នាំ២០២០